រដ្ឋសភា

# ច្បាប់

## ស្តីពី

# ការបង្ការ និង ការប្រយុទ្ធទប់ស្កាត់
# ការរីករាលដាល
# មេរោគអេដស៍ / ជំងឺអេដស៍

## ( HIV / AIDS )

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
បោះពុម្ពដោយថវិកាជាតិ ឆ្នាំ ២០០៦

# ព្រះរាជក្រម

នស/រកម/០៧០២/០១៥

រដ្ឋសភា
លេខ :............
ថ្ងៃទី..... ខែ..... ឆ្នាំ២០០.....
បញ្ជូនទៅ............

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

[illegible] ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាល ទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១០ ខែ កក្កដាឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា១. ‒

ច្បាប់នេះមានគោលដៅកំណត់ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២. ‒

ជំងឺអេដស៍ គឺជាជំងឺឆ្លងរីករាលដាលមួយបង្កឡើងដោយមេរោគអេដស៍ និងដែលទទួលស្គាល់ថា គ្មានព្រំដែនផ្នែកផែនដី សង្គម នយោបាយនិងសេដ្ឋកិច្ច ហើយជំងឺនេះពុំទាន់មានថ្នាំព្យាបាលឱ្យជាសះស្បើយទេ។ ការរីករាល-ដាលនៃជំងឺនេះ បាននឹងកំពុងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសន្តិសុខ ស្ថិរភាពនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ដែលទាមទារឱ្យរដ្ឋចាត់វិធានការ ឆ្លើយតបជាពហុវិស័យ ដើម្បី:

១- ជំរុញឱ្យមានការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋគ្រប់រូបស្តីពីមូលហេតុ របៀបនៃការចម្លង ផលវិបាក មធ្យោបាយបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) តាមរយៈកម្មវិធីអប់រំ និង យុទ្ធនាការផ្សព្វផ្សាយទូលំ-ទូលាយទូទាំងប្រទេស។

២- ហាមឃាត់ការរើសអើងគ្រប់ប្រភេទ ចំពោះរាល់បុគ្គលណាដែលត្រូវបានសង្ស័យ ឬត្រូវបានដឹងថាមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)។

៣- ជំរុញឱ្យមានការប្រុងប្រយ័ត្នជាសាកល ចំពោះវិធីសាស្ត្រ និង ការអនុវត្តន៍ទាំងឡាយដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)។

៤- ចាត់វិធានការសមស្រប ចំពោះរាល់កត្តាទាំងឡាយដែលធ្វើឱ្យកាន់តែធ្ងន់ធ្ងរដល់ការរីករាលដាល

មេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)។

៥- លើកទឹកចិត្តឱ្យមានតួនាទីជាសក្កានុពលរបស់បុគ្គលដែលមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ក្នុងការលាតត្រដាងពត៌មាន និងបទពិសោធន៍របស់ពួកគេ ដើម្បីចង្អុលបង្ហាញដល់សាធារណជន។

៦-បញ្ចូលកម្មវិធីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ជាកម្មវិធីអាទិភាព ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ។